# សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ

នៅថ្ងៃ ពុធ ទី **២០ ខែ មីនា ឆ្នាំ ២០២៤** វេលាម៉ោង ៤ រសៀល ក្រុមហ៊ុនវិនិយោគសហគមន៍ក្រុងឡុងប៊ិច (CIC) នឹងរៀបចំសវនាការជាសាធារណៈមួយនៅជាន់ទីពីរនៅសាលសន្និសីទរបស់សាលាក្រុង បិតនៅអគារលេខ 411 West Ocean Boulevard, Long Beach។

គោលបំណងនៃសវនាការនេះ គឺដើម្បីផ្តល់ឱកាសជូនសាធារណជនក្នុងការបញ្ចេញមតិអំពីការអភិវឌ្ឍនៃផែនការសកម្មភាពឆ្នាំសារពើពន្ធ ២០២៤-២០២៥ ដើម្បីដោះស្រាយបញ្ហាអាទិភាពនៃផែនការរួមក្នុងពេលបច្ចុប្បន្ន។ ជារៀងរាល់ឆ្នាំ សាលាក្រុងឡុងប៊ិចទទួលបានប្រាក់ពីនាយកដ្ឋានលំនៅឋាន និងការអភិវឌ្ឍទីក្រុងរបស់សហរដ្ឋអាមេរិក (HUD) ដើម្បីជួយកែលម្អភូមិឋានរបស់យើង។ មូលនិធិនេះបានមកពីប្រភពចំនួនបី៖ ថវិកាជំនួយដែលសម្រាំងទុកសម្រាប់អភិវឌ្ឍន៍សហគមន៍ (CDBG), ថវិកាជំនួយសម្រាប់ដោះស្រាយបញ្ហាថាមពល (ESG), និងច្បាប់ស្តីពីការដៃគូវិនិយោគផ្ទែកលំនៅឋាន (HOME)។

សាលាក្រុងឡុងប៊ិច មានបំណងផ្តល់ជូនការសម្របសម្រួលសមស្រប សម្រាប់បងប្អូនពិការដែលមានបំណងចង់មកចូលរួមក្នុងសវនាការនេះ ដោយយើងប្រតិបត្តិតាមច្បាប់ស្តីពីជនពិការអាមេរិក (ADA) ឆ្នាំ ១៩៩០។ បើបងប្អូនត្រូវការឲ្យមានកិច្ចសម្របសម្រួលពិសេសណាមួយសម្រាប់បងប្អូនជនពិការ សូមទូរស័ព្ទទៅកាន់អ្នកស្រី Elizabeth Weithers តាមលេខ៖ (562) 570-6912 ដោយទាក់ទងអ្នកស្រីឲ្យបានយ៉ាងហោចណាស់ ៤៨ ម៉ោង នៅមុនសវនាការសាធារណៈ នៅថ្ងៃទី ២០ ខែ មីនានោះ។ បងប្អូនប្រជាពលរដ្ឋដែលមានបំណងចង់ផ្តល់ជាមតិជាលាយលក្ខណ៍អក្សរ បងប្អូនត្រូវធ្វើដូច្នេះឲ្យបានត្រឹមថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២៤។ មតិជាលាយលក្ខណ៍អក្សរ អាចផ្ញើទៅជូនអ្នកស្រី Elizabeth Weithers តាមអាសយដ្ឋាននេះ៖ Community Development Department, 411 West Ocean Boulevard, Long Beach, California 90802 ឬផ្ញើតាមអ៊ីម៉េលទៅកាន់អ្នកស្រី Elizabeth.Weithers@longbeach.gov។

បងប្អូនអាចស្នើព័ត៌មាននេះជាទម្រង់ផ្សេងពីនេះ ឬស្នើសុំឲ្យមានការសម្របសម្រួលសមស្របណាមួយសម្រាប់បងប្អូនពិការ។ សូមបងប្អូនទាក់ទងទៅខាងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ តាមគេហទំព័រ longbeach.gov/lbcd and 562.570.3807។ យើងខ្ញុំត្រូវការពេលយ៉ាងហោចណាស់បីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីសម្របស្រួលដោះស្រាយតាមសំណូមពររបស់បងប្អូន។ ទោះជាយ៉ាងនេះក្តី យើងខ្ញុំនឹងខិតខំដោះស្រាយតាមសំណូមពរដែលដាក់ស្នើយឺតជាងរយៈពេលនេះ។